គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការកណ្តាល

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

# សេចក្តីថ្លែងការណ៍
# របស់គណបក្សប្រជាជនកម្ពុជា

**គណបក្សប្រជាជនកម្ពុជា** សូមប្រកាសបដិសេធ និងទាត់ចោលទាំងស្រុងនូវឯកសារក្លែងក្លាយ ដោយប្រើរូបភាពជា " សេចក្តីថ្លែងការណ៍របស់គណបក្សប្រជាជនកម្ពុជា " ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលត្រូវបានបង្កើតឡើងដោយជនទុច្ចរិត ប្រើប្រាស់គណនីហ្វេសប៊ុកឈ្មោះ " អ្នកស្នេហាជាតិ គណបក្សប្រជាជនកម្ពុជា " និងគេហទំព័រហ្វេសប៊ុកឈ្មោះ " Ar Kambang Knong Ar Kambang " ហើយត្រូវបានចែកចាយដោយទណ្ឌិត សម រង្ស៊ី នៅក្នុងគេហទំព័ររបស់ខ្លួន នៅព្រឹកថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៩ ក្នុងគោលបំណងញុះញង់បំបែកបំបាក់គណបក្សប្រជាជនកម្ពុជា បង្កភាពវឹកវរក្នុងសង្គម និងបំផ្លាញដំណើរការអភិវឌ្ឍប្រទេសជាតិ ។

**គណបក្សប្រជាជនកម្ពុជា** ថ្កោលទោសយ៉ាងដាច់អហង្ការចំពោះទង្វើឧក្រិដ្ឋដ៏ធ្ងន់ធ្ងរនេះ និងសូមប្តឹងដល់ស្ថាប័នមានសមត្ថកិច្ចចាត់វិធានការជាបន្ទាន់ ដើម្បីរកមុខរកជនដែលពាក់ព័ន្ធនឹងបទល្មើសខាងលើ យកមកផ្តន្ទាទោសឱ្យបានម៉ឺងម៉ាត់បំផុតតាមច្បាប់ជាធរមាន ។

**គណបក្សប្រជាជនកម្ពុជា** ស្ថិតនៅជានិច្ចជាមួយប្រជាជន ដើម្បីបន្តថែរក្សាសន្តិភាព និងការអភិវឌ្ឍ ។ គណបក្សប្រជាជនកម្ពុជាទាំងមូលមានសាមគ្គីភាព ឯកភាពផ្ទៃក្នុងខ្ពស់ និងគោរពនូវតួនាទីជាប្រវត្តិសាស្ត្រដ៏ឧត្តុង្គឧត្តមបំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ដែលជាស្នូលនៃគណបក្សប្រជាជនកម្ពុជា និងជាអគ្គមគ្គុទ្ទេសក៏ដ៏ឆ្នើមរបស់ប្រជាជនកម្ពុជា ។

ថ្ងៃ សុក្រ ៤កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៩

**គណបក្សប្រជាជនកម្ពុជា**